រាជធានីភ្នំពេញ ,ថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ២៩ សសរ

## ស្តីពីការ បង្កើតគណៈកម្មការស្រាវជ្រាវអំពីគំពេងគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រាសាទព្រះវិហារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ ១៩៩៧
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតច្រកទ្វារព្រំដែនកម្ពុជា- ថៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍
- យោងតាមស្មារតីអង្គប្រជុំអន្តរក្រសួង នាថ្ងៃទី ១៩ ខែមីនា ឆ្នាំ១៩៩៩

## សំរេច

**ប្រការ ១ ៖** ត្រូវបានបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវអំពីគំពាងគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រាសាទព្រះវិហារ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម សូ ម៉ារ៉ា អគ្គនាយកក្រសួងទេសចរណ៍ | | ប្រធាន |
| ឧត្តមសេនីយ៍ទោ ជា សារ៉ែន មេបញ្ជាការរង កងទ័ពជើងគោកក្រសួង ការពារជាតិ | | អនុប្រធាន |
| ៣-លោក អភិបាលរងខេត្តព្រះវិហារ | | សមាជិក |
| ៤-លោក ហួន សារ៉ាង | ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងជាសមាជិកអាជ្ញាធរជាតិ ទទួលបន្ទុកកិច្ច ការព្រំដែន | សមាជិក |
| ៥-លោក ឧង នីនាង | អនុប្រធាននាយកដ្ឋានជនបរទេស ក្រសួងមហាផ្ទៃ | សមាជិក |
| ៦-លោក សំ សុផល | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៧-លោក ឡូម ច័ន | ប្រធាននាយកដ្ឋានអភិរក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៨-លោក ស៊ារ កុសល | អនុប្រធាននាយកដ្ឋានច្បាប់និងកុងស៊ុលក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |

៩-លោក សាន ផាន់នី អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

ប្រការ ២ : គណៈកម្មការសិក្សាស្រាវជ្រាវអំពីគំរោងគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រាសាទ ព្រះវិហារ មានភារកិច្ចដូចតទៅ ៖

- ធ្វើការសិក្សាអំពីរូបភាពនៃការគ្រប់គ្រងនិងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រាសាទព្រះវិហារ ដោយ ធានាបានសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ ជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ការពារបរិស្ថានធម្មជាតិ និងវប្បធម៌បេតិកភ័ណ្ឌប្រវត្តិសាស្ត្ររបស់ជាតិដោយ ឈរលើ :
- លក្ខណៈបច្ចេកទេសខាងវិស័យទេសចរណ៍
- និដ្ឋភាពច្បាប់
- ការគិតគូរដល់អធិបតេយ្យភាព និងបូរណភាពដែនដីរបស់ព្រះរាជាណាចក្រកម្ពុជា ស្តីពីការ បញ្ហាព្រំដែន
- ស្មារតីសហប្រតិបត្តិការអោយបានល្អជាមួយប្រទេសថៃ ជាលក្ខណៈអន្តរជាតិ និងប្រទេស ជិតខាង
- ស្មារតីរក្សាការពារបេតិកភ័ណ្ឌជាប្រវត្តិសាស្ត្ររបស់ជាតិ និងជំនឿសាសនាអោយបាន ស្ថិតស្ថេរចិរកាល កុំអោយរងគ្រោះដោយសារការបំផ្លិចបំផ្លាញ
- ធានាសន្តិសុខសុវត្ថិភាពសណ្តាប់ធ្នាប់របៀបរៀបរយ
- ការគិតគូរពីរូបភាពគ្រប់គ្រងនិងរបៀបផ្ទេរពីការកាន់កាប់របស់កងទ័ពមកអ្នកគ្រប់គ្រងថ្មី។

ប្រការ ៣ : គណៈកម្មការនេះមានលេខាធិការដ្ឋាននៅក្រសួងទេសចរណ៍ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួង ទេសចរណ៍ ដើម្បីសំរួលការងារ ។

ប្រការ ៤ : សមាជិកគណៈកម្មការសក្សាស្រាវជ្រាវអំពីគំរោងគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រាសាទ ព្រះវិហារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៥ : គណៈកម្មការនេះត្រូវរៀបចំគំរោងស្តីពីការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រាសាទព្រះ វិហារ មកអោយទីស្តីការគណៈរដ្ឋមន្ត្រីអោយបានឆាប់បំផុត ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីសំរេច ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន និងអភិបាលខេត្ត ព្រះវិហារ និងអស់លោកដែលមានចែងឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន